# ប្រាក់ឧបត្ថម្ភជំនួយសង្គ្រោះថ្លៃឈ្នួលផ្ទះ COVID-19

## សំណួរ និងចម្លើយ

### តើប្រាក់ឧបត្ថម្ភជំនួយសង្គ្រោះថ្លៃឈ្នួលផ្ទះជាអ្វី?

រដ្ឋាភិបាលរដ្ឋវិចថូរៀ បានបង្កើតមូលនិធិជំនួយថ្លៃឈ្នួលផ្ទះចំនួន 80 លានដុល្លារសម្រាប់ប្រជាជនដែលជួលផ្ទះរបស់ពួកគេ។

មូលនិធិនេះអាចមានផ្តល់សម្រាប់ពលរដ្ឋវិចថូរៀ ដែលបានបាត់បង់ប្រាក់ចំណូលដោយសារការឆ្លងរាលដាលនៃវីរុសកូរ៉ូណា (COVID-19)។

ពលរដ្ឋវិចថូរៀដែលកំពុងមានការពិបាកក្នុងការបង់ថ្លៃជួលផ្ទះរបស់ពួកគេ អាចមានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភរហូតដល់ទៅ 3,000 ដុល្លារ។

### តើអ្នកណាមានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភជំនួយសង្គ្រោះថ្លៃឈ្នួលផ្ទះ?

ដើម្បីមានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភ អ្នកនឹងចាំបាច់ត្រូវ៖

- យល់ព្រមលើការកាត់បន្ថយថ្លៃឈ្នួលជាមួយម្ចាស់ផ្ទះរបស់អ្នក ហើយចុះបញ្ជីកិច្ចព្រមព្រៀងលើការជួលថ្មីជាមួយក្រសួងកិច្ចការអតិថិជន រដ្ឋវិចថូរៀ (Consumer Affairs Victoria)។ ប្រសិនបើអ្នកមិនអាចឈានដល់កិច្ចព្រមព្រៀងជាមួយម្ចាស់ផ្ទះរបស់អ្នកទេ អ្នកអាចស្វែងរកជំនួយពីក្រសួងកិច្ចការអតិថិជន រដ្ឋវិចថូរៀ
- ប្រាក់ចំណូលរបស់អ្នកត្រូវតែតិចជាង 1,903 ដុល្លារក្នុងមួយសប្តាហ៍
- ហើយអ្នកត្រូវតែមានប្រាក់សន្សំតិចជាង 10,000 ដុល្លារ។

មិនមានតម្រូវការលើភាពជាសញ្ជាតិ ឬការស្នាក់នៅជាអចិន្ត្រៃយ៍សម្រាប់អ្នកដាក់ពាក្យសុំទេ។

### តើខ្ញុំអាចដាក់ពាក្យសុំប្រាក់ឧបត្ថម្ភជំនួយសង្គ្រោះយ៉ាងដូចម្តេច?

ប្រសិនបើអ្នកបានចុះបញ្ជីកិច្ចព្រមព្រៀងលើការជួលថ្មីជាមួយក្រសួងកិច្ចការអតិថិជន រដ្ឋវិចថូរៀ អ្នកអាចដាក់ពាក្យសុំប្រាក់ឧបត្ថម្ភជំនួយសង្គ្រោះថ្លៃឈ្នួលផ្ទះតាមអនឡាញ តាមរយៈ <https://rentrelief.covid19.dhhs.vic.gov.au/>។

### តើប្រាក់ឧបត្ថម្ភអាចប្រើសម្រាប់អ្វីខ្លះ?

ប្រសិនបើប្រាក់ឧបត្ថម្ភរបស់អ្នកត្រូវបានយល់ព្រម ប្រាក់នេះនឹងត្រូវបានបើកឱ្យផ្ទាល់ទៅម្ចាស់ផ្ទះរបស់អ្នក ជាឥណទានសម្រាប់ការទូទាត់កិច្ចព្រមព្រៀងលើការជួលថ្មីរបស់អ្នក។

### តើខ្ញុំអាចរកព័ត៌មានបន្ថែមទៀតនៅទីណា?

សម្រាប់ព័ត៌មានថ្មីៗបំផុតស្តីពីប្រាក់ឧបត្ថម្ភជំនួយសង្គ្រោះ COVID-19 សូមចូលមើល <https://www.housing.vic.gov.au/help-renting/rentrelief>

ដើម្បីចុះបញ្ជីកិច្ចព្រមព្រៀងលើការជួលថ្មីរបស់អ្នក ឬស្វែងរកជំនួយពីក្រសួងកិច្ចការអតិថិជន រដ្ឋវិចថូរៀ សូមចូលមើល <https://www.consumer.vic.gov.au/resources-and-tools/advice-in-a-disaster/coronavirus-covid19-and-your-rights/renting-rules-and-support-during-the-moratorium>

ប្រសិនបើអ្នកត្រូវការជំនួយពីអ្នកបកប្រែភាសាជាមួយនឹងមានព័ត៌មានណាមួយខាងលើនេះ សូមទូរស័ព្ទទៅសេវាកម្មបកប្រែភាសាសរសេរ និងនិយាយ (TIS National) លេខ 131 450។

អនុញ្ញាត និងបោះពុម្ពផ្សាយដោយរដ្ឋាភិបាលរដ្ឋវិចថូរៀ 1 Treasury Place, Melbourne។

© រដ្ឋវិចថូរៀ អូស្ត្រាលី ក្រសួងសុខាភិបាល និងសេវាកម្មមនុស្ស (Department of Health and Human Services) ខែកញ្ញា ឆ្នាំ 2020។

VICTORIA State Government | Health and Human Services